01249217

002/19-09-2007-ECCC/TC
E1/424

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 06 / 2016
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>សាធារណៈ</u>**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៨ ខែ មេសា ឆ្នាំ ២០១៦

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៤០៥

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង Evelyn CAMPOS SANCHEZ

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ , ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde D' ESTMAEL , កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លីវ សុវណ្ណា, លោកស្រី Doreen CHEN |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD , លោក ពេជ អង្គ, លោកស្រី ជេត វណ្ណលី, លោក ឡោ ជុនធី, លោកស្រី ទី ស្រីនណា, លោក វ៉េន ពៅ, លោក ហុង គីមសួន |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ លោក ប្រាក់ ខន (2-TCW-931) |
| មេធាវីប្រឹក្សា៖ លោក ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោកស្រី ពេជ ចរិយា, លោកស្រី សំ មករា, លោក វ៉ាត សុម៉ៅ, កញ្ញា យស់ សេរីរ័ត្ន, កញ្ញា Natalie GUNARIDIS |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៨.៥៩ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣០ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៤.៥៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣១ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៨.៥៩ | ០៩.០១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០១ | ០៩.០២ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី ប្រាក់ ខន (2-TCW-931) | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ<br><br><br><br>មេធាវីការពារក្តី នួន ជា | ០៩.០២<br>០៩.២៥<br>១០.០០<br>១០.៣០<br>១៥.១៦<br>១៥.៥៧<br>១០.៤៧<br>១៣.៣១<br>១៥.០០ | ០៩.២៥<br>០៩.៥៩<br>១០.១២<br>១០.៣៦<br>១៥.២០<br>១៦.០២<br>១១.២៨<br>១៤.៤០<br>១៥.៥៤ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចផ្ទាល់មាត់ទៅលើការជំទាស់របស់សហព្រះរាជអាជ្ញាក្នុងការតាំងសំណួរទៅសាក្សី ទាក់ទងនឹងខ្លឹមសារនៃចម្លើយសារភាពមន្ទីរស-២១ ដែលត្រូវបានសន្មតថា ទទួលបានពីការធ្វើទារុណកម្ម | សហព្រះរាជអាជ្ញា | ១៥.០៨ | ១៥.០៩ |
| | | ១៥.១៣ | ១៥.១៤ |
| | | ១៥.២០ | ១៥.២១ |
| | មេធាវីការពារក្ដី នួន ជា | ១៥.០៩ | ១៥.១២ |
| | | ១៥.១៤ | ១៥.១៤ |
| | | ១៥.២១ | ១៥.២៤ |
| | អង្គជំនុំជម្រះ | ១៥.១៤ | ១៥.២០ |
| | | ១៥.២៤ | ១៥.២៥ |
| | | ១៥.២៩ | ១៥.២៩ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការបន្តតាំងសំណួរទៅកាន់សាក្សី ប្រាក់ ខន (2-TCW-931)**

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ និង មេធាវីការពារក្ដី នួន ជា បានតាំងសំណួរទៅសាក្សី ប្រាក់ ខន (2-TCW-931) ។

**សេចក្ដីសម្រេចផ្ទាល់មាត់ទៅលើការជំទាស់របស់សហព្រះរាជអាជ្ញាលើការតាំងសំណួរទៅសាក្សីទាក់ទងនឹងខ្លឹមសារនៅក្នុងចម្លើយសារភាពដែលសន្មតថាទទួលបានពីការធ្វើទារុណកម្ម។**

សហព្រះរាជអាជ្ញាបានលើកឡើងថា មានការសន្មតថារាល់ចម្លើយសារភាពទាំងអស់ដែលបានពីអ្នកទោសនៅមន្ទីរស-២១ សុទ្ធតែទទួលបានបន្ទាប់ពីមានការធ្វើទារុណកម្ម ទោះជាដោយមានការវាយដំ ឬមិនបានវាយដំក៏ដោយ ឱ្យតែអ្នកទោសទាំងនោះត្រូវបានឃុំឃាំងនៅក្នុងស្ថានភាពបន្ទាបបន្ថោក មិនមែនជាមនុស្ស និងត្រូវបានគេចាត់ទុកដូចជាសត្វធាតុ។ ពួកគេត្រូវបានទទួលរងនូវការគម្រាមកំហែងនៅពេលសួរចម្លើយ និងមានការបោកបញ្ឆោតដើម្បីឱ្យអ្នកទោសឆ្លើយសារភាព។ ទោះបីជាលក្ខខណ្ឌទាំងនេះ

ធ្វើឡើងដើម្បីឲ្យអ្នកទោសឆ្លើយក៏ដោយ ក៏ការគម្រាមកំហែងទាំងនេះស្ថិតនៅក្នុងនិយមន័យនៃការធ្វើទារុណកម្មដែលបានកំណត់នៅក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មដែរ។ ដូច្នេះ សហព្រះរាជអាជ្ញាបានផ្តល់ទឡ្ហីករណ៍ថា គ្រប់ភស្តុតាងដែលបានមកពីចម្លើយសារភាព ដែលបានធ្វើដោយអ្នកទោសនៅមន្ទីរស-២១ គឺមិនអាចទទួលយកបានទេ ទោះបីជាមិនមានការវាយដំ ឬមានការវាយដំនៅក្នុងអំឡុងពេលនៃការសួរចម្លើយអ្នកទោសក៏ដោយ។

មេធាវីការពារក្តី នួន ជា បានលើកឡើងបង្ហាញពីចម្លើយផ្សេងគ្នាដែលធ្វើដោយអ្នកទោសឈ្មោះ ឆុន នៅមន្ទីរស-២១ នៅក្នុងចម្លើយសារភាពរបស់គាត់នៅមុនពេល និងក្រោយពេលធ្វើទារុណកម្ម ដោយសាក្សី ប្រាក់ ខន (2-TCW-931) នៅក្នុងអំឡុងពេលគាត់សួរចម្លើយ។ សាក្សីបានផ្តល់សក្ខីកម្មពីពេលមុនថា នៅថ្ងៃដែលគាត់បានវាយទៅ ឆុន ដោយប្រើមែកឈើនោះ គឺក្រោយពេលដែល ឆុន បានផ្តល់ចម្លើយសារភាពរួចហើយ ប៉ុន្តែមិនបានពេញលេញ។ មេធាវីការពារក្តី បានសួរទៅសាក្សីថា តើចម្លើយសារភាពនោះធ្វើឡើងនៅមុនពេលដែលគាត់វាយដំទៅ ឆុន មែនដែរ ឬទេ។ ហេតុដូច្នេះ ចម្លើយនោះមិនមែនទទួលបានដោយការធ្វើទារុណកម្មនោះទេ។ មេធាវីការពារក្តី បានយោងទៅលើចម្លើយសារភាពនេះដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ពួកគេដែលថា ការឃុំឃាំង ឆុន និងអ្នកជាប់ឃុំមួយចំនួនទៀត ត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ដោយសារតែពួកគេជាជនសង្ស័យដែលប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹងរដ្ឋាភិបាល ដែលវាជាបទល្មើសនៅក្នុងប្រទេសមួយចំនួន។ មេធាវីការពារក្តី បានរក្សានៅអំណះអំណាងដែលថា បញ្ហានេះគឺជាចំណុចកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏ដូចជាអង្គហេតុដែលបានកំណត់នៅក្នុងសាលក្រម ឌុច ដែលបានសម្រេចពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួន ដែលខុសច្បាប់ ហើយដែលមេធាវីការពារក្តីបានលើកឡើងថាវាខុសពីករណីនេះ។

អង្គជំនុំជម្រះបានសម្រេចថា ការប្រើប្រាស់ចម្លើយសារភាពដែលបានធ្វើដោយ ឆុន ស្ថិតនៅក្នុងករណីដែលត្រូវបានហាមឃាត់ ដោយសារតែការឆ្លើយនេះមានការបង្ខិតបង្ខំដោយប្រើទារុណកម្ម ដោយផ្អែកទៅតាមសេចក្តីសម្រេចភាគច្រើនរបស់អង្គជំនុំជម្រះទាក់ទងនឹងការប្រើប្រាស់ភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម។

Reclassified

| TC No. | OCIJ No. | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/2117 | | 00192933-00193063; 00081277-00081488; 00762103- | Book concerning the history of Khmer Rouge Division 703, a military unit comprised of soldiers | P | / | / | 0008130 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00762110 | from Sector25 who were considered to be among the elite forces of the DK military | | | | |
| E3/965 | | 00068840-00068843; 00316312-00316318; 00324630-00324636 | Brief Story of people who set free | P | 00068840 | 00316312 | 00324630 |
| E3/8778 | | 00989308-00989329 | DC-Cam PA Field Reports | P | / | / | / |
| E3/2007 | | 00039568-00039573; 00233755-00233765; 00863798-00863807 | List of prisoners from ministry and devers zones interrogated by Chewing Group and Documentation Group | P | 00039568 | 00233755 | 00863798 |
| E3/7540 | | 00053774-00053774, 00055071-0005508; 00184133-00184135, 00337707-0033772; 00364268-00364284 | DC-Cam Statement of THACH Siek | P | 00055078-00055079 | 00337712 | 00364274 |
| E3/834 | | 00077442-00077660; 00184483-00184529; 00235437-00235439 | Pon's uncatalogued 21-page document in DC-Cam's archive dated 7-12 December 1976 | P | 00077476 | / | / |
| E3/3365 | | 00656306-00656308; 00445199-00445200; 00664005-00664006 | LA Times article, "MILLIONS SENT TO RETRAINING ZONES; Red Forces Purifying Cambodia" | P | / | / | / |
| E3/9749 | | 00963839-00964053; 00898209-00898330; 00955348-00955474 | Booked by Sydney SCHANBERG entitled: "Cambodia Diary 1975 – A jounalist's day-by-day notes on the fall of Cambodia to the | P | / | / | 00955412-00955414 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | Khmer Rouge" | | | | |
| E3/3939 R | | / V 00172512-00172512; V 00172512-00172512 | Video excerpt entitled "Pol Pot et Les Khmer Rouges" | P | / | / | / |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/832 | | 00068914-00068964 | The Execution Order | P | 00068920 | 00068921 | / |
| E3/7639 | | 00162706-00162717; 00162729-00162741; 00338071-00338084 | Written Record of Interview of NIM Kim Sreang | P | 00162713; 00162710 | 00162736; 00162733 | 00338079; 00338076 |
| E3/833 | | 00077661-00078056; 00184579-00184579; 00282468-00282547 | S-21 Notebook by MAM Nai alias Chan | P | 0007729; 00077740: 00077826; 00077946 | 00184591; 00184614 | 00282536; 00282547 |
| E3/13 | | 00053402-00052416; 00940336-00940358; 00334972-00334984 | Note of Secretary meeting, vice secretary, and regiment about Situation to defense the country and the measure to defense the country | P | 00052414 | 00940354-00940355 | 00334983 |
| E3/1549 | | 00174392-00174434; 00769683-00769715; 00965737-00965779 | 555bbkkh Colour copy Excerpt of Confession of Eng Meng Heang alias Chhon | P | 00174428 | 00769710 | / |
| E3/4260 | | 00257986-00258112; 00782970-00782984; | S-21 Confession of EM Min alias SEN | P | 00257995 | 00782984 | / |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00803385-00803396 | | | | | |
| E3/1570 | | 00154220-00154233; 00154220-00154233; 00154204-00154219 | Written Record of Interview of Duch by CIJ on 29-11-2007 | P | / | 00154192 | / |
| E3/1822 | | 00338995-00339006; 00078437-00078604; 00758327-00758335 | OUKOUBAH, By Ysa OSMAN | P | / | 00078508 | / |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០២)
- អង្គជំនុំជម្រះបានហាម មេធាវីការពារក្តី មិនឱ្យប្រើប្រាស់ចម្លើយដែលមាននៅក្នុងចម្លើយសារភាពរបស់ ឈុន នៅក្នុងអំឡុងពេលនៃការតាំងសំណួរទៅសាក្សី ប្រាក់ ខន 2-TCW-931 ដោយសារតែចម្លើយសារភាពនោះអាចនឹងទទួលបានពីការធ្វើទារុណកម្ម។ (១៥.២៨)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦។ (១៦.០៧)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុល[illegible] Evelyn CAMPOS SANCHEZ